# សេចក្តីថ្លែងការណ៍រួម

## "ច្បាប់សិទ្ធិទទួលព័ត៌មានលើកកម្ពស់សេវាសាធារណៈ និងការអភិវឌ្ឍប្រកបដោយចីរភាព"

## ពន្លឿនការអនុម័តច្បាប់សិទ្ធិទទួលព័ត៌មានដើម្បីលើកកម្ពស់សេវាសាធារណៈ និងការអភិវឌ្ឍប្រកបដោយចីរភាព

សង្គមស៊ីវិល ស្នើអោយរាជរដ្ឋាភិបាល និងស្ថាប័នសភាជាតិអនុម័តច្បាប់សិទ្ធិទទួលព័ត៌មានឱ្យបានឆាប់ស្របតាមបទដ្ឋានអន្តរជាតិ និងធានាបាននូវសិទ្ធិសេរីភាពក្នុងការទទួលបានព័ត៌មានដើម្បីលើកកម្ពស់សេវាសាធារណៈ និងដំណោះស្រាយបញ្ហាប្រឈមនានាលើគ្រប់វិស័យ ។

បច្ចុប្បន្ននេះប្រជាជនកម្ពុជា នៅមានកង្វល់អំពីការទទួលបានព័ត៌មានសាធារណៈនៅឡើយ ព្រោះទាំងរដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ នៅមានភាពស្ទាក់ស្ទើរក្នុងការបើកចំហ ឬ ផ្សព្វផ្សាយព័ត៌មានមួយចំនួនដោយសារ ខ្វះខាតធនធាន សមត្ថភាពមានកម្រិត បើទោះជាមានបញ្ញត្តិខ្លះបានកំណត់ពីតួនាទី និង ការទទួលខុសត្រូវរបស់រដ្ឋបាលសាធារណៈក្នុងការបើកចំហ ឬផ្សព្វ ផ្សាយព័ត៌មានក៏ដោយ។

ការរីករាលដាលនៃកូវីដ ១៩ នាពេលបច្ចុប្បន្នបានបង្ហាញឱ្យឃើញពីសារៈសំខាន់ និងការអនុវត្តសិទ្ធិទទួលព័ត៌មាន ក្នុងវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាលមានភាពសកម្ម និងចូលរួមចំណែកក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌ មាននៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការផ្តល់ និងទទួលព័ត៌មានសេវាសាធារណៈផ្សេងៗទៀត មាន ការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ដែលប៉ះពាល់ជាយថាហេតុដល់សិទ្ធិ និងផលប្រយោជន៍នានា ដូចជាកិច្ចសន្យាដីសម្បទាន សេដ្ឋកិច្ច គម្រោងអភិវឌ្ឍធំៗ គម្រោងលទ្ធកម្មសាធារណៈថ្នាក់ជាតិ បញ្ហាដីធ្លី ការបណ្តេញចេញដោយបង្ខំ និងវិវាទ ដទៃទៀត។

អង្គការសង្គមស៊ីវិល និងយុវជនទទួលស្គាល់ការខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន ជាពិសេសនៅថ្នាក់ក្រោមជាតិ តាមរយៈកម្មវិធីមួយចំនួនដូចជា អភិបាលកិច្ចល្អមូលដ្ឋាន ក្របខ័ណ្ឌគណនេយ្យភាពសង្គម ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និង ច្រកចេញចូលតែមួយជាដើម។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមដំណើរការធ្វើសេចក្តីព្រាង ច្បាប់ស្តីពីសិទ្ធិ

ទទួលព័ត៌មាន ទទួលបានការកោតសរសើរ ហើយក្រុមការងារអង្គការសង្គមស៊ីវិល ក៏គាំទ្រយ៉ាងភ្លៀវភ្លា ចំពោះប្រសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ក្នុងជំនួបជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី៣ និង នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ នាជំនួបជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី៤ ចំពោះការធានាឱ្យមានច្បាប់សិទ្ធិទទួលព័ត៌មានក្នុងនីតិកាលទី៦នេះ។ បច្ចុប្បន្ននេះសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មានបានបញ្ចប់ការត្រួតពិនិត្យលើមាត្រាស្តីពីទោសបទប្បញ្ញត្តិពីក្រសួងយុត្តិធម៌ និងបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី វិញហើយ។

ក្នុងជំនួបរវាង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី ៥ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ នេះ ក្រុមយុវជន ក្រុមមនុស្សចាស់ អង្គការសង្គមស៊ីវិលក្រុមការងារលើកកម្ពស់សិទ្ធិទទួលព័ត៌មាននៃអង្គការមិនមែនរដ្ឋាភិបាល សូមស្នើជូន **សម្តេច** និង រាជរដ្ឋាភិបាល៖

- ពន្លឿនការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលស្របតាមបទដ្ឋានអន្តរជាតិ។
- សូមបញ្ជាក់ឱ្យបានច្បាស់អំពីព័ត៌មានណាខ្លះជាប្រភេទព័ត៌មានសម្ងាត់ ក្នុងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ។
- ក្រសួង មន្ទីរ និងអង្គភាពនានារបស់រដ្ឋ ត្រូវបើកចំហព័ត៌មានសាធារណៈឱ្យបានទូលំទូលាយ ជាពិសេស តម្លៃសេវាកម្មនីតិវិធីក្នុងការទទួលបានសេវា និងពេលវេលាកំណត់ដោយច្បាប់នៅកម្រិតថ្នាក់ជាតិ កិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច គម្រោងអភិវឌ្ឍធំៗ គម្រោងលទ្ធកម្មសាធារណៈថ្នាក់ជាតិ បញ្ហាដីធ្លី ការបណ្តេញចេញដោយបង្ខំ និងវិវាទដ៏ទៃទៀត។
- ពង្រឹង និងបង្កើតនូវយន្តការទាំងឡាយជាពិសេសយកចិត្តទុកដាក់លើការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធានាថាប្រជាពលរដ្ឋ ក្រុមយុវជន ជនមានពិការភាព និងជនជាតិដើមភាគតិចទទួលបាននូវព័ត៌មានពេញលេញ។
- ផ្តល់កិច្ចការពារចំពោះប្រជាពលរដ្ឋគ្រប់រូបដែលបានបង្ហាញ និងចែកចាយនូវព័ត៌មានពិតប្រាកដ ឬ ព័ត៌មានទាំងឡាយណាដែលបម្រើដល់ប្រយោជន៍សាធារណៈ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពី សិទ្ធិទទួលបានព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋជាពិសេស យុវជនឱ្យចូលរួមក្នុងការស្វែងរកព័ត៌មានសាធារណៈទាំងឡាយដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ។
- បង្កើតឱ្យមានបរិយាកាសកាន់តែប្រសើរឡើង សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋជាពិសេសយុវជនក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២៣

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**១ .លោក ឡាំ សុជាតិ នាយកប្រតិបត្តិវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ( API )**

តំណាងអង្គការសង្គមស៊ីវិលចំនួន ២៥ធ្វើការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន( A2IWG )

ទូរស័ព្ទ៖ ០១២ ៧១៨ ៦១១

**២ .លោក បិច ពិសី នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា**

ទូរស័ព្ទ៖ ០១៦ ២០៥ ៨០៧

**៣ .លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ( ខេមបូចា )**

ទូរស័ព្ទ៖ ០១២ ៥១៩ ២៦១